00357931

D158/5/1/14

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Préliminaire

**សំណុំរឿងព្រហ្មទណ្ឌលេខ:** ០០២/១៩-០៩-២០០៧/អវតក/កសចស (អបជ~~១៩~~,~~២០~~,២១ ~~និង ២២~~)

**ចំពោះមុខ:**
ចៅក្រម ប្រាក់ គឹមសាន, ប្រធាន
ចៅក្រម Rowan DOWNING
ចៅក្រម នីយ ថុល
ចៅក្រម Katinka LAHUIS
ចៅក្រម ហួត វុទ្ធី

**កាលបរិច្ឆេទ:** ៤ សីហា ឆ្នាំ២០០៩

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 04 / AUG / 2009
ម៉ោង (Time/Heure): 14:10
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

សាធារណៈ

## សេចក្តីសម្រេចលើសំណើសុំការអនុញ្ញាតដាក់*សារណារបស់អ្នកមិនមែនជាភាគីនៃរឿងក្តី*

**សហព្រះរាជអាជ្ញា**
ជា លាង
Robert PETIT
យ៉ែត ចរិយា
William SMITH
តាន់ សេណារ៉ុង
Anees AHMED

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 04 / 08 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

**ជនត្រូវចោទ**
អៀង ធីរិទ្ធ
អៀង សារី
នួន ជា
ខៀវ សំផន

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**
ហុង គឹមសួន
ឡោ ជុនធី
នី ចាន់ឌី
គង់ ពិសី
យុង ផានិត
គឹម ម៉េងឃី
ម៉ុច សុវណ្ណារី
Silke STUDZINSKY
Martine JACQUIN
Philippe CANONNE
Pierre Olivier SUR
Elizabeth RABESANRATANA
Olivier BAHOUGNE
David BLACKMAN
Annie DELAHAIE

**ដើមបណ្តឹងរដ្ឋប្បវេណីគ្មានមេធាវីតំណាង**

**សហមេធាវីការពារក្តីជនត្រូវចោទ**
ផាត់ ពៅសៀង
Diana ELLIS
អាង ឧត្តម
Michael G. KARNAVAS
សុន អរុណ
Michiel PESTMAN
ស សុវាន
Jacques VERGES

E.C.C.C * C.E.T.C PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

០០២/១៩-០៩-២០០៧/អវតក/កសចស(អបជ~~១៩,២០~~,២១ ~~និង២២~~)

~~PTC19: D158/5/4/13~~
~~PTC20: D158/5/3/14~~
PTC21: D158/5/1/14
~~PTC22: D158/5/2/14~~

១. **អង្គបុរេជំនុំជម្រះ** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“អ.វ.ត.ក”) បានទទួលលិខិតមួយច្បាប់ ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៩ (ដែលមានភ្ជាប់មកជាមួយ) ពី Elezabeth Nielsen ដែលជាមន្ត្រីជំនួយផ្នែកច្បាប់នៃមជ្ឈមណ្ឌលឯកសារកម្ពុជា (DC-Cam) ដែលក្នុងលិខិតនោះ មានការស្នើសុំការអនុញ្ញាតដាក់សារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី ទាក់ទិនទៅនឹង “ការជាប់ពាក់ព័ន្ធនៃការចោទប្រកាន់ពីអំពើពុករលួយនៅ អ.វ.ត.ក ក្នុងការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌”។

២. វិធាន ៣៣(១) នៃវិធានផ្ទៃក្នុងចែងថា ៖

> “នៅគ្រប់ដំណាក់កាលនៃដំណើរការនីតិវិធី បើយល់ថាចាំបាច់ដើម្បីវិនិច្ឆ័យទោសឱ្យបានត្រឹមត្រូវ សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះអាចអញ្ជើញ ឬផ្តល់ឱកាសឱ្យអង្គការ ឬបុគ្គលណាមួយប្រគល់ជូននូវសារណាជាលាយលក្ខណ៍អក្សរ ពាក់ព័ន្ធទៅនឹងបញ្ហាណាមួយក៏បានក្នុងនាមជាអ្នកឯកទេសអមតុលាការ។ សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះ ដែលពាក់ព័ន្ធត្រូវកំណត់ពេលវេលាឱ្យដាក់សារណានេះ ប្រសិនបើត្រូវធ្វើ”។

៣. អង្គបុរេជំនុំជម្រះយល់ឃើញថា តាមរយៈសារណារបស់ភាគីចំពោះបណ្តឹងឧទ្ធរណ៍ អង្គបុរេជំនុំជម្រះនឹងទទួលបានព័ត៌មានគ្រប់គ្រាន់ ដើម្បីធ្វើការសម្រេចលើបណ្តឹងឧទ្ធរណ៍នេះ។ អង្គបុរេជំនុំជម្រះយល់ឃើញទៀតថា វាជាការមិនគប្បីក្នុងការប្រថុយប្រថាននឹងការពន្យារពេលដំណើរការនីតិវិធី ដោយទទួលយកសារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី និងសេចក្តីសន្និដ្ឋានតបទៅនឹងសារណាទាំងនេះពីភាគីទាំងឡាយឡើយ។

៤. អង្គបុរេជំនុំជម្រះ សូមថ្លែងអំណរអរគុណចំពោះចំណាប់អារម្មណ៍របស់ Elezabeth Nielsen នៅក្នុងដំណើរការនីតិវិធីថ្មីៗនេះ ប៉ុន្តែ អង្គបុរេជំនុំជម្រះពិចារណាឃើញថា វាមិនមែនជាការល្អប្រសើរ ក្នុងការអនុញ្ញាតតាមការស្នើសុំដាក់សារណានៅក្នុងរឿងក្តីនេះឡើយ។

០០២/១៩-០៩-២០០៧/អវតក/កសចស(អបជ~~១៩,២០,~~២១ ~~និង២២~~)

~~PTC19: D158/5/4/13~~
~~PTC20: D158/5/3/14~~
PTC21: D158/5/1/14
~~PTC22: D158/5/2/14~~

**ដូច្នេះ អង្គបុរេជំនុំជម្រះ ៖**

បដិសេធសំណើសុំការអនុញ្ញាតដាក់សារណារបស់*អ្នកដែលមិនមែនជាភាគីនៃរឿងក្តី*។

ភ្នំពេញ ថ្ងៃទី ៤ ខែសីហា ឆ្នាំ២០០៩

**ប្រធានអង្គបុរេជំនុំជម្រះ**

PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE
E.C.C.C * C.E.

**ប្រាក់ គឹមសាន**

00357934

០០២/១៩-០៩-២០០៧/អវតក/កសចស(អបជ~~១៩,២០~~,២១ ~~និង២២~~)

~~PTC19: D158/5/4/13~~
~~PTC20: D158/5/3/14~~
PTC21: D158/5/1/14
~~PTC22: D158/5/2/14~~

អង្គបុរេជំនុំជម្រះ
អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
ផ្លូវជាតិលេខ ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ ក្រុងភ្នំពេញ

ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៩

ជូនចំពោះ : ប្រធានអង្គបុរេជំនុំជម្រះជាទីគោរព ៖

នាងខ្ញុំឈ្មោះ Elizabeth Nielsen ជាមន្ត្រីជំនួយផ្នែកច្បាប់ នៅឆ្នាំ២០០៩ នៃមជ្ឈមណ្ឌលឯកសារកម្ពុជា (DC-Cam)។ មជ្ឈមណ្ឌលឯកសារកម្ពុជាបានតាមដានយ៉ាងសកម្មទៅលើដំណើរការនីតិវិធីរបស់ អ.វ.ត.ក ចាប់តាំងពីពេលចាប់ផ្តើមរបស់តុលាការនេះ។ ជាមន្ត្រីជំនួយផ្នែកច្បាប់ និងជាអ្នកប្រកបវិជ្ជាជីវៈច្បាប់ទូទៅម្នាក់ នាងខ្ញុំមានការចាប់អារម្មណ៍យ៉ាងខ្លាំងនៅក្នុងការធានាថា អ.វ.ត.ក ប្រកាន់ខ្ជាប់ទៅនឹងគោលការណ៍ច្បាប់អន្តរជាតិ។ ការធ្វើបែបនេះ អ.វ.ត.ក នឹងបំពេញបេសកកម្មរបស់ខ្លួនក្នុងការផ្តល់យុត្តិធម៌ចំពោះឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ នៅក្នុងប្រទេសកម្ពុជា។

នាងខ្ញុំសូមស្នើអង្គជំនុំជម្រះផ្តល់ការអនុញ្ញាតឲ្យនាងខ្ញុំ ដាក់ជូនសារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី អនុលោមតាមវិធានផ្ទៃក្នុង ៣៣ ទាក់ទិនទៅនឹងការជាប់ពាក់ព័ន្ធនៃការចោទប្រកាន់ពីអំពើពុករលួយនៅ អ.វ.ត.ក ក្នុងការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌។ ការចោទប្រកាន់ពីអំពើពុករលួយនៅ អ.វ.ត.ក គឺជាបញ្ហានៃការព្រួយបារម្ភមួយដ៏ធ្ងន់ធ្ងរ ដូចដែលបានបញ្ជាក់ដោយបណ្តឹងវិវាទនៅមានជាបន្ត នៅលើសំណើរបស់ក្រុមមេធាវីការពារក្តី នួន ជា ដែលក្នុងសំណើនោះត្រូវបានចូលរួមពីក្រុមមេធាវី អៀង សារី, អៀង ធីរិទ្ធ, និង ខៀវ សំផន ហើយត្រូវបានគាំទ្រពីសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី សុំឲ្យធ្វើការស៊ើបអង្កេតទៅលើការចោទប្រកាន់ពីអំពើពុករលួយ និងបង្ហាញនូវលទ្ធផលនៃរបាយការណ៍របស់ UN-OIOS ស្តីពីអំពើពុករលួយ។ សេចក្តីសម្រេចអំពីការជាប់ពាក់ព័ន្ធនៃការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ គឺមានសារៈសំខាន់ខ្លាំងណាស់ចំពោះដំណើរការនីតិវិធីទាំងមូលរបស់តុលាការ ហើយដូច្នេះសេចក្តីសម្រេចនោះគួរតែត្រូវធ្វើឡើងបន្ទាប់ពីបានធ្វើការពិចារណាទៅលើសេចក្តីសន្និដ្ឋានជាធរមាន និងប្រភពនៃការវិភាគផ្នែកច្បាប់ជាមុនសិន។

តុលាការនេះអាចទទួលបានផលប្រយោជន៍ ក្នុងការទទួលយកសារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី ពីភាគីដែលមានអព្យាក្រឹត ដែលមិនមានការជាប់ពាក់ព័ន្ធទៅនឹងការិយាល័យណាមួយឡើយរបស់តុលាការនេះ។ សារណាទាំងនេះ ផ្តល់ឱ្យតុលាការនូវទិដ្ឋភាពទាំងស្រុង និងលម្អិតនៃយុត្តិសាស្ត្រ ទាក់ទិនទៅនឹងបញ្ហាសំខាន់ៗនៃច្បាប់ ដែលអាចត្រូវបានលើកឡើងនៅចំពោះមុខ អ.វ.ត.ក។ ដូច្នេះ សារណាទាំងនេះ អាចជាផ្នែកមួយដ៏មានសារៈសំខាន់បន្ថែមទៅនឹងការស៊ើបអង្កេតដោយផ្ទាល់របស់តុលាការ នៅពេលធ្វើសេចក្តីសម្រេចទៅលើបញ្ហាច្បាប់ដ៏មានសារៈសំខាន់ និងស្មុគស្មាញ ដូចជាការជាប់ពាក់ព័ន្ធនៃការចោទប្រកាន់ពីអំពើពុករលួយនៅ អ.វ.ត.ក ក្នុងការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌។

ផ្អែកទៅលើហេតុផលដែលបានបញ្ជាក់ជូនខាងលើនេះ សូមអង្គ [បុរេ] ជំនុំជម្រះមេត្តាទទួលយកសារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី ដែលមានភ្ជាប់មកជាមួយ ទាក់ទិនទៅនឹងបញ្ហានៃការជាប់ពាក់ព័ន្ធនៃការចោទប្រកាន់ពីអំពើពុករលួយនៅ អ.វ.ត.ក ទៅនឹងក្នុងការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌។ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ។ នាងខ្ញុំរង់ចាំការឆ្លើយតបពីលោកប្រធាន។

ដោយសេចក្តីគោរព

ELIZABETH NIELSEN
elizabeth.nielsen@yale.edu
*Juris Doctor*, Yale Law School
មន្ត្រីជំនួយផ្នែកច្បាប់ ឆ្នាំ២០០៩ នៃមជ្ឈមណ្ឌលឯកសារកម្ពុជា (DC-Cam)

PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C. C.E.T.C.